អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
លេខ...០៤៦.........អ.ស.ហ.ប្រក

# ប្រកាស
# ស្តីពី
# ការបោះផ្សាយលក់សញ្ញាបណ្ណរដ្ឋជាបែតងសម្ព័ន្ធ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២១/០១៨ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២២ ស្តីពីការដាក់ឱ្យប្រើនីតិវិធីគ្រប់គ្រងប្រតិបត្តិការរួមសម្រាប់គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន
- បានឃើញប្រកាសលេខ ០០៩/១៧ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១៧ ស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ
- បានឃើញប្រកាសលេខ ០០៧/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ ស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម
- បានឃើញប្រកាសលេខ ០១១/១៨ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ
- បានឃើញប្រកាសលេខ ០០៦/២០ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២០ ស្តីពីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ
- បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំលើកទី២៤ អាណត្តិទី១ នាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

### ប្រការ១ .-

ប្រកាសនេះកំណត់អំពីលក្ខខណ្ឌ នីតិវិធីនៃការបោះផ្សាយ និងកាតព្វកិច្ចក្រោយការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព គណនេយ្យភាព និងតម្លាភាព។

### ប្រការ២ .-

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធជាសាធារណៈ ការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធជាឯកជន និងការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសម្រាប់វិនិយោគិនគុណវុឌ្ឍិ ព្រមទាំងបុគ្គលពាក់ព័ន្ធនឹងប្រតិបត្តិការនេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ប្រការ៣ .-

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន ប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម ប្រកាសស្តីពីអភិបាលកិច្ចសាជីវកម្មសម្រាប់

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ និងប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ ៖

១-**ក្រុមហ៊ុនមានគោលបំណងពិសេស** (Special Purpose Vehicle) សំដៅដល់សហគ្រាសដែលត្រូវបានបង្កើតឡើងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយជាភាគីតំណាង ឬអ្នកកៀរគរទុន ដើម្បីប្រើប្រាស់ក្នុងគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

២-**ក្រុមហ៊ុនឧបត្ថម្ភធន** (Sponsor) សំដៅដល់ក្រុមហ៊ុន ឬសហគ្រាសដែលរៀបចំ និងចាត់ចែងប្រតិបត្តិការទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធតាមរយៈការផ្ទេរទ្រព្យសកម្មទាំងស្រុង ឬដោយប្រយោលទៅឱ្យក្រុមហ៊ុនបោះផ្សាយមូលបត្រ។

៣-**ទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធ** (Infrastructure Asset) សំដៅដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ឬប្រព័ន្ធដែលនឹងត្រូវសាងសង់ និង/ឬប្រតិបត្តិការ ដើម្បីផ្តល់សេវាសាធារណៈដោយផ្ទាល់ ឬដោយប្រយោល ដែលគាំទ្រដល់មុខងារ និងផលិតភាពនៃសេដ្ឋកិច្ច និងសង្គមនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤-**មូលបត្រនីយកម្ម** (Securitization) សំដៅដល់ដំណើរការដែលបម្លែងបណ្តុំទ្រព្យសកម្មមួយ ឬច្រើនទៅជាមូលបត្រដើម្បីលក់ទៅវិនិយោគិន ដោយមានការធានាពីគណនីត្រូវទទួលនៃបណ្តុំទ្រព្យសកម្មទាំងនេះ។

៥-**មូលបត្របំណុលបន្ទាប់បន្សំ** សំដៅដល់មូលបត្របំណុលដែលមានអាទិភាពទាបជាងបំណុលថ្នាក់ខ្ពស់នៅពេលសងត្រឡប់វិញ។

៦-**សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្ម** សំដៅដល់សញ្ញាបណ្ណដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុនជំនាញហេដ្ឋារចនាសម្ព័ន្ធ ដើម្បីធ្វើហិរញ្ញប្បទាន ឬបុនហិរញ្ញប្បទាន ការអភិវឌ្ឍ ការសាងសង់ ប្រតិបត្តិការ និងការថែទាំទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធ។

៧-**សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោង** សំដៅដល់សញ្ញាបណ្ណដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុនជំនាញហេដ្ឋារចនាសម្ព័ន្ធ ដែលត្រូវបានបង្កើតឡើងជាក្រុមហ៊ុនមានគោលបំណងពិសេសដោយក្រុមហ៊ុនឧបត្ថម្ភធនសម្រាប់គោលបំណងជាក់លាក់ក្នុងការកាន់កាប់ទ្រព្យសកម្មរបស់គម្រោង។

៨-**សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធមូលបត្រនីយកម្ម** (Infrastructure Securitization Bond) សំដៅដល់សញ្ញាបណ្ណដែលត្រូវបានបោះផ្សាយដោយក្រុមហ៊ុនមានគោលបំណងពិសេសដែលបានបង្កើតឡើងដោយក្រុមហ៊ុនជំនាញហេដ្ឋារចនាសម្ព័ន្ធដែលជាក្រុមហ៊ុនដើម (Originator)។ **ក្រុមហ៊ុនដើម** ជាក្រុមហ៊ុនដែលមានគណនីត្រូវទទួល ប្រាក់កម្ចី ឬទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងទៀត ដែលនឹងបញ្ចូលក្នុងបណ្តុំទ្រព្យសកម្ម។

## ជំពូកទី២
## លក្ខខណ្ឌតម្រូវសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ

### ប្រការ៤ _

សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធអាចត្រូវបានបោះផ្សាយដោយក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ឬនីតិបុគ្គលប្រតិស្រុត ក្នុងទម្រង់ជាសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្ម សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោង ឬសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធមូលបត្រនីយកម្ម។

ការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធមូលបត្រនីយកម្មត្រូវកំណត់នៅក្នុងបទប្បញ្ញត្តិដោយ-ឡែក។

សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធអាចជាសញ្ញាបណ្ណធម្មតា សញ្ញាបណ្ណមានវត្ថុធានា ឬសញ្ញាបណ្ណមានបុគ្គលធានា។

**ប្រការ៥ ._**

សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មអាចត្រូវបានបោះផ្សាយលក់ជាឯកជន បោះផ្សាយលក់ជាសាធារណៈ ឬបោះផ្សាយលក់សម្រាប់វិនិយោគិនគុណវុឌ្ឍិ។

សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងអាចត្រូវបានបោះផ្សាយលក់ជាឯកជន ឬបោះផ្សាយលក់សម្រាប់វិនិយោគិនគុណវុឌ្ឍិដោយក្រុមហ៊ុនមានគោលបំណងពិសេស។

បុគ្គលដែលមានបំណងធ្វើសំណើលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធជាឯកជន ជាសាធារណៈ ឬសម្រាប់វិនិយោគិនគុណវុឌ្ឍិ ត្រូវស្នើសុំការអនុញ្ញាតពីនិយ័តករមូលបត្រកម្ពុជា (**ន.ម.ក.**) និងបំពេញលក្ខខណ្ឌតម្រូវតាមបញ្ញត្តិជាធរមាន។

**ប្រការ៦ ._**

ទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធត្រូវស្ថិតនៅក្នុងចំណោមផ្នែកណាមួយដូចខាងក្រោម៖

១-គមនាគមន៍។

២-ការបង្កើតថាមពលកកើតឡើងវិញ។

៣-ការបង្កើតថាមពលមិនកកើតឡើងវិញ។

៤-ការផ្ទុក ការបញ្ជូន និងការចែកចាយ ថាមពល។

៥-ផលិតកម្មកែច្នៃថាមពល។

៦-ថាមពលទូទៅ។

៧-សង្គម។

៨-ទូរគមនាគមន៍។

៩-ទឹក។

១០-កាកសំណល់។

១១-បរិស្ថាន។ ឬ

១២-ផ្សេងៗ។

**ន.ម.ក.** អាចផ្តល់ការអនុញ្ញាតលើទ្រព្យសកម្មជាក់លាក់ណាមួយដែលមិនមាននៅក្នុងទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធមានលក្ខណសម្បត្តិគ្រប់គ្រាន់ដូចមានក្នុងកថាខណ្ឌទី១ ខាងលើ។

ទ្រព្យសកម្មមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលត្រូវបានប្រើប្រាស់សម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធត្រូវកំណត់ដោយគោលការណ៍ណែនាំរបស់ **ន.ម.ក.**។

**ប្រការ៧ ._**

សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធត្រូវបានយកមកប្រើប្រាស់សម្រាប់៖

១-ការធ្វើហិរញ្ញប្បទានលើគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្មី។

២-ការធ្វើបុនហិរញ្ញប្បទានលើប្រាក់កម្ចីដែលមានស្រាប់។

៣-ការធ្វើឱ្យប្រសើរឡើង និងទំនើបកម្មទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់។

៤-ការថែទាំ និងប្រតិបត្តិការនៃទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធ។

៥-ការពង្រីកបណ្តាញហេដ្ឋារចនាសម្ព័ន្ធ។

៦-ការផ្តួចផ្តើមនៃបរិស្ថាន និងចីរភាព។

៧-គម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន (Public-Private Partnership Projects)។

៨-ការលើកកម្ពស់ប្រសិទ្ធភាពគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

៩-ការប្រើប្រាស់ផ្សេងទៀតដែលត្រូវបានអនុញ្ញាតដោយ **ន.ម.ភ.**។

សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធមិនត្រូវបានប្រើប្រាស់ដោយក្រុមហ៊ុនបោះផ្សាយមូលបត្រ ឬក្រុមហ៊ុនឧបត្ថម្ភធន សម្រាប់គោលបំណងផ្សេងទៀតឡើយ លុះត្រាតែមានការអនុញ្ញាតពី **ន.ម.ភ.**។

**ប្រការ៨ .-**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មជាសាធារណៈ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ៦ ប្រការ៧ និងប្រការ៨ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មសម្រាប់វិនិយោគិនគុណវុឌ្ឍិ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ៧ និងប្រការ៨ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌតម្រូវបន្ថែមដូចខាងក្រោម៖

១-អនុវត្តស្របតាមលក្ខខណ្ឌទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងការប្រើប្រាស់សាច់ប្រាក់ ដូចមានកំណត់ក្នុងប្រការ៦ និងប្រការ៧ នៃប្រកាសនេះ។

២-មានបទពិសោធន៍ក្នុងការគ្រប់គ្រងទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធ ដែលមានលក្ខណៈដូច ឬប្រហាក់-ប្រហែលគ្នានឹងទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធដែលគ្រោងនឹងបោះផ្សាយ លើកលែងតែមានការអនុញ្ញាតផ្សេងពី **ន.ម.ភ.**។

៣-មាននិរន្តរភាព និងសមិទ្ធិលទ្ធភាព (Viability and Feasibility) នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

៤-ទទួលបានការធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **ន.ម.ភ.**។

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្ម ក្នុងគោលបំណងបៃតង សង្គម ឬចីរភាព បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌតម្រូវបន្ថែមតាមការកំណត់របស់ **ន.ម.ភ.**។

**ប្រការ៩ .-**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងសម្រាប់វិនិយោគិនគុណវុឌ្ឍិត្រូវបំពេញលក្ខខណ្ឌតម្រូវដូចមានចែងក្នុងប្រការ៧ និងប្រការ៨ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្រ

បំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ និងត្រូវមានរបាយការណ៍ហិរញ្ញវត្ថុព្យាករណ៍សម្រាប់រយៈពេលនៃឥណប្រតិទានរបស់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោង។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌតម្រូវបន្ថែមដូចខាងក្រោម៖

១-អនុវត្តស្របតាមលក្ខខណ្ឌទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធមានលក្ខណសម្បត្តិគ្រប់គ្រាន់ និងការប្រើប្រាស់សាច់ប្រាក់ ដូចមានកំណត់ក្នុងប្រការ៦ និងប្រការ៧ នៃប្រកាសនេះ។

២-មាននិរន្តរភាព និងសមិទ្ធិលទ្ធភាព (Viability and Feasibility) នៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

៣-ទទួលបានការធ្វើចំណាត់ថ្នាក់លទ្ធភាពសងពីភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ពី **ន.ម.ក**។

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោង ក្នុងគោលបំណងបៃតង សង្គម ឬចីរភាព បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌតម្រូវបន្ថែមតាមការកំណត់របស់ **ន.ម.ក**។

**ប្រការ១០ .-**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោង ក្រុមហ៊ុនមានគោលបំណងពិសេសត្រូវបង្កើតឡើងដោយក្រុមហ៊ុនឧបត្ថម្ភធន យ៉ាងតិច ១ (មួយ)។

ក្រុមហ៊ុនមានគោលបំណងពិសេសដែលបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងត្រូវបំពេញនូវលក្ខខណ្ឌដូចខាងក្រោម៖

១-ជាក្រុមហ៊ុន ឬសហគ្រាសដែលចុះបញ្ជីពាណិជ្ជកម្មស្របច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-មានគោលបំណងជាក់លាក់ដូចជា រចនាប្លង់ អភិវឌ្ឍន៍ ថែទាំ ឬដំណើរការទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងប្រការ៦ នៃប្រកាសនេះ។

៣-ជានីតិបុគ្គលដាច់ដោយឡែកពីក្រុមហ៊ុនមេ ឬក្រុមហ៊ុនហូលឌីង ហើយកាតព្វកិច្ចទាំងអស់របស់ក្រុមហ៊ុនមានគោលបំណងពិសេសត្រូវបានធានា ទោះបីជាក្រុមហ៊ុនមេត្រូវក្ស័យធនក៏ដោយ។

៤-ត្រូវគ្រប់គ្រងដោយអភិបាលឯករាជ្យ និងអភិបាលដែលមានជំនាញវិជ្ជាជីវៈពាក់ព័ន្ធ។

៥-មិនត្រូវមានកម្មវត្ថុអាជីវកម្ម ឬសិទ្ធិអំណាចដើម្បីធ្វើសកម្មភាពណាផ្សេងទៀតក្រៅពីកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុនមានគោលបំណងពិសេសដែលធ្វើការបោះផ្សាយ។

៦-ត្រូវមានសេវាកម្ម និងកាតព្វកិច្ច ដាច់ដោយឡែកពីក្រុមហ៊ុនមេ ឬក្រុមហ៊ុនហូលឌីង។

៧-ត្រូវអនុវត្តតួនាទីប្រកបដោយសុចរិត និងស្មោះត្រង់។

៨-មិនត្រូវមានការទទួលខុសត្រូវណាមួយចំពោះភាគីទីបី ក្រៅពីភាគីដែលពាក់ព័ន្ធក្នុងប្រតិបត្តិការនៃការបោះផ្សាយលក់សញ្ញាបណ្ណឡើយ។

៩-ត្រូវមានលទ្ធភាពទូទាត់សងបំណុលបច្ចុប្បន្ន និងបំណុលអនាគតរបស់ក្រុមហ៊ុនមានគោលបំណងពិសេសដោយផ្អែកលើរបាយការណ៍លំហូរសាច់ប្រាក់ព្យាករណ៍ និងរបាយការណ៍ចំណូលព្យាករណ៍។

១០-ត្រូវទទួលខុសត្រូវចំពោះការបំពេញមុខងារ ឬមិនបំពេញមុខងាររបស់បុគ្គលដែលក្រុមហ៊ុនមានគោលបំណងពិសេសប្រគល់ឱ្យ។ ក្រុមហ៊ុនមានគោលបំណងពិសេសត្រូវទទួលខុសត្រូវទាំងស្រុងដើម្បីធានាថាទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធមានលក្ខណសម្បត្តិគ្រប់គ្រាន់ត្រូវបានគ្រប់គ្រងដោយយកចិត្តទុកដាក់ និងជាផលប្រយោជន៍របស់ម្ចាស់មូលបត្របំណុល។

១១-ត្រូវធានាថាការផ្ដល់សេវាកម្មដែលទាក់ទងនឹងទ្រព្យសកម្មហេដ្ឋារចនាសម្ព័ន្ធមានលក្ខណសម្បត្តិគ្រប់គ្រាន់ត្រូវបានធ្វើឡើងក្រោមលក្ខខណ្ឌទីផ្សារ។

១២-ត្រូវមានគណនី និងកំណត់ត្រាផ្ទាល់ខ្លួនដាច់ដោយឡែកពីក្រុមហ៊ុនឧបត្ថម្ភធន ដើម្បីបង្ហាញថាទ្រព្យសកម្ម បំណុល ចំណូល និងចំណាយរបស់ក្រុមហ៊ុនមានលក្ខណៈពេញលេញនិងត្រឹមត្រូវ ហើយអនុលោមតាមលក្ខខណ្ឌតម្រូវនៃការរាយការណ៍ស្របតាមបទប្បញ្ញត្តិផ្សេងទៀតទាក់ទងនឹងការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោង។

**ន.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនមានគោលបំណងពិសេសមានវត្ថុធានា ឬមានបុគ្គលធានាដោយផ្អែកលើការបោះផ្សាយលក់មូលបត្របំណុល។

ក្រុមហ៊ុនឧបត្ថម្ភធននៃក្រុមហ៊ុនមានគោលបំណងពិសេស ត្រូវមានរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្រ និង/ឬរបាយការណ៍ហិរញ្ញវត្ថុប្រវត្តិសាស្ត្ររួមរយៈពេល ២ (ពីរ) ឆ្នាំនៃការិយបរិច្ឆេទគណនេយ្យចុងក្រោយ ដែលត្រូវធ្វើសវនកម្មស្របតាមច្បាប់និងបទដ្ឋានគតិយុត្តជាធរមានសម្រាប់ក្រុមហ៊ុនឧបត្ថម្ភធននៃក្រុមហ៊ុនមានគោលបំណងពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងស្របតាមស្តង់ដាអន្តរជាតិឬស្តង់ដាដែលសមមូលសម្រាប់ក្រុមហ៊ុនឧបត្ថម្ភធននៃក្រុមហ៊ុនមានគោលបំណងពិសេសដែលជាក្រុមហ៊ុនបរទេស។ ក្រុមហ៊ុនឧបត្ថម្ភធននៃក្រុមហ៊ុនមានគោលបំណងពិសេសត្រូវផ្ដល់របាយការណ៍ហិរញ្ញវត្ថុក្នុងគ្រា ករណីក្រុមហ៊ុនមានគោលបំណងពិសេសដាក់ពាក្យស្នើសុំនៅក្រោយរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃបន្ទាប់ពីដំណាច់ត្រីមាស។

ក្រុមហ៊ុនឧបត្ថម្ភធននៃក្រុមហ៊ុនមានគោលបំណងពិសេសត្រូវបានលើកទឹកចិត្តឱ្យអនុវត្តអភិបាលកិច្ចសាជីវកម្មស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

## ប្រការ១១.-

បុគ្គលចុះបញ្ជីលក់មូលបត្រដែលមានបំណងបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធត្រូវបានលើកលែងលក្ខខណ្ឌតម្រូវពីការបញ្ជាក់ជាមុនអំពីការពិនិត្យលទ្ធភាពអាចចុះបញ្ជីលក់មូលបត្រពីផ្សារមូលបត្រប្រតិស្រុត។

## ប្រការ១២.-

បុគ្គលដាក់ពាក្យស្នើសុំត្រូវដាក់ជូន **ន.ម.ក.** នូវឯកសារដូចខាងក្រោម៖

១-ពាក្យស្នើសុំតាមការកំណត់ដោយ **ន.ម.ក.**។

២-ឯកសារផ្ដល់ព័ត៌មាន។

៣-ឯកសារភ្ជាប់ដូចខាងក្រោម៖

ក-ឯកសារភ្ជាប់ដូចមានចែងក្នុងប្រការ១០ នៃប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មជាសាធារណៈ ឬឯកសារភ្ជាប់ដូចមានចែងក្នុងប្រការ១០ នៃប្រកាសស្ដីពីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មសម្រាប់វិនិយោគិនគុណវុឌ្ឍិ ឬករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងសម្រាប់វិនិយោគិនគុណវុឌ្ឍិ។

ខ-របាយការណ៍អំពីនិរន្តរភាព និងសមិទ្ធិលទ្ធភាពនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

គ-របាយការណ៍ចំណាត់ថ្នាក់លទ្ធភាពសង ដែលចេញដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសងដែលទទួលបានការទទួលស្គាល់ដោយ **ន.ម.ភ.**។

ឃ-ផែនការនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

ង-ឯកសារភ្ជាប់បន្ថែមសម្រាប់ការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងសម្រាប់វិនិយោគិនគុណវុឌ្ឍិ ដូចខាងក្រោម៖

- កិច្ចព្រមព្រៀងទិញ (Off-Take) ឬកិច្ចព្រមព្រៀងបង់ប្រាក់ផ្សេងទៀត។
- កិច្ចព្រមព្រៀងប្រតិបត្តិការ និងការថែទាំ។
- កិច្ចព្រមព្រៀងវិស្វកម្ម លទ្ធកម្ម និងសាងសង់។
- កិច្ចព្រមព្រៀងអន្តរម្ចាស់បំណុល (ប្រសិនមាន)។
- អាជ្ញាបណ្ណ ឬការអនុញ្ញាតដែលមាន។
- កិច្ចព្រមព្រៀងសម្បទាន (ប្រសិនមាន)។
- ការអនុញ្ញាតបរិស្ថាន ឬរបាយការណ៍ស្តីពីបរិស្ថាន សង្គម និងអភិបាលកិច្ច (ESG Report)។

ច-ឯកសារបន្ថែមករណីបុគ្គលដាក់ពាក្យស្នើសុំជាដៃគូឯកជនដែលបានជ្រើសរើសក្នុងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជននៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ ដូចខាងក្រោម៖

- កិច្ចសន្យាភាពជាដៃគូរវាងរដ្ឋនិងឯកជន (ភ.រ.ជ.)។
- កិច្ចព្រមព្រៀងនវកម្ម (Novation Agreement)។
- ឯកសារពាក់ព័ន្ធគាំទ្រគម្រោង ភ.រ.ជ.។

ឆ-ឯកសារផ្សេងទៀតដែលតម្រូវដោយ **ន.ម.ភ.**។

## ជំពូកទី៣
## ការអនុញ្ញាតលើការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ

**ប្រការ១៣ .-**

ករណីស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មជាសាធារណៈ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញព័ត៌មានដូចមានចែងក្នុងប្រការ១២ និងប្រការ២២ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ករណីស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មសម្រាប់វិនិយោគិនគុណវុឌ្ឍិ ឬសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងសម្រាប់វិនិយោគិនគុណវុឌ្ឍិ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញព័ត៌មានដូច-មានចែងក្នុងប្រការ១១ និងប្រការ១២ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ។

ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញព័ត៌មានអំពីការប្រើប្រាស់សាច់ប្រាក់សរុបដែលបានមកពីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធស្របទៅតាមផែនការនៃការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយ ដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ ដោយបញ្ជាក់អំពីចំនួនទឹកប្រាក់ដែលត្រូវប្រើប្រាស់សម្រាប់គោលដៅនីមួយៗ។ ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីដំណាក់កាលនានានៃការអនុវត្ត និងការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ។ ករណីសាច់ប្រាក់ដែលបានមកពីការបោះផ្សាយ

ត្រូវបានប្រើប្រាស់នៅក្នុងកិច្ចសន្យារវាងបុគ្គលដាក់ពាក្យស្នើសុំ និងភាគីទីបី ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីរយៈពេលសុពលភាពនៃកិច្ចសន្យាទាំងនេះ។ ករណីការស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងផែនការវិនិយោគរបស់ក្រុមហ៊ុន ឯកសារផ្តល់ព័ត៌មានត្រូវបង្ហាញពីផែនការវិនិយោគនោះ។ ករណីផែនការវិនិយោគមានលើសពី ១ (មួយ) ផែនការនីមួយៗត្រូវបង្ហាញដាច់ពីគ្នា ជាទម្រង់ពេញលេញក្នុងឯកសារផ្តល់ព័ត៌មាន។

ឯកសារផ្តល់ព័ត៌មានរបស់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងសម្រាប់វិនិយោគិនគុណវុឌ្ឍិត្រូវបង្ហាញព័ត៌មានបន្ថែមដូចខាងក្រោម៖

១-ផែនការនៃគម្រោងហេដ្ឋារចនាសម្ព័ន្ធ។

២-រចនាសម្ព័ន្ធលម្អិតអំពីភាគីពាក់ព័ន្ធនៅក្នុងគម្រោង។

៣-ការពន្យល់អំពីលំហូរនៃមូលនិធិ លំហូរអាទិភាពនៃការទូទាត់ រួមទាំងព័ត៌មានស្តីពីសាច់ប្រាក់ដែលជាប់គាំង និងការវិនិយោគដែលមានការអនុញ្ញាតសម្រាប់សាច់ប្រាក់ដែលលើស។

៤-ព័ត៌មានលម្អិតអំពីក្រុមហ៊ុនឧបត្ថម្ភធន កាតព្វកិច្ច និងការរឹតត្បិត របស់ក្រុមហ៊ុនឧបត្ថម្ភធន។

៥-ហានិភ័យសំខាន់ៗក្នុងការវិនិយោគលើសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោង។

៦-ព័ត៌មានស្តីពីការលើកកម្ពស់ឥណទាន (Credit Enhancement) និងកិច្ចសន្យាសន្ទនីយភាព (ប្រសិនមាន) និងបង្ហាញពីចំណុចខ្វះខាតសំខាន់ៗដែលរំពឹងថានឹងកើតឡើង។

៧-ព័ត៌មានលម្អិតអំពីម្ចាស់បំណុលធំៗ (Controlling Creditor) និងពេលវេលាដែលម្ចាស់បំណុលធំៗអាចអនុវត្តសិទ្ធិរបស់ខ្លួន នៅពេលដែលអ្នកកាន់កាប់មូលបត្របំណុលជាម្ចាស់បំណុលបន្ទាប់បន្សំ និងនៅពេលដែលម្ចាស់បំណុលធំៗ មានសិទ្ធិក្នុងការកែប្រែលក្ខខណ្ឌដាក់លាក់នៃមូលបត្របំណុល។

៨-របាយការណ៍ហិរញ្ញវត្ថុព្យាករណ៍សម្រាប់រយៈពេលនៃឥណប្រតិទានរបស់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោង។

៩-របាយការណ៍របស់អ្នកជំនាញ ដោយព័ត៌មានផ្តល់ដោយក្រុមហ៊ុនឧបត្ថម្ភធន និងប្រភពព័ត៌មានច្បាស់លាស់ផ្សេងទៀត។

១០-ព័ត៌មានពាក់ព័ន្ធនឹងទំនាស់ផលប្រយោជន៍ជាសក្តានុពល ឬជាក់ស្តែង (ប្រសិនមាន)។

**ប្រការ១៤ ._**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មជាសាធារណៈ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវអនុវត្តប្រការ២៣ ប្រការ២៤ ប្រការ២៥ ប្រការ២៦ ប្រការ២៧ នៃជំពូកទី៣ ជំពូកទី៤ និងជំពូកទី៥ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មសម្រាប់វិនិយោគិនគុណវុឌ្ឍិ ឬការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងសម្រាប់វិនិយោគិនគុណវុឌ្ឍិ ក្រុមហ៊ុនបោះផ្សាយមូលបត្រត្រូវអនុវត្តប្រការ១៣ ប្រការ១៤ ប្រការ១៥ ប្រការ១៦ នៃជំពូកទី៣ និងជំពូកទី៤ នៃប្រកាសស្តីពីការបោះផ្សាយមូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ។

## ជំពូកទី៤
## លក្ខខណ្ឌតម្រូវក្រោយការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ

**ប្រការ១៥ ._**

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មជាសាធារណៈ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវអនុវត្តជំពូកទី៤ នៃប្រកាសនេះ ប្រកាសស្តីពីការបង្ហាញព័ត៌មានសាជីវកម្ម និងប្រការ៤១ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលជាសាធារណៈ។

ករណីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធសាជីវកម្មសម្រាប់វិនិយោគិនគុណវុឌ្ឍិ ឬសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងសម្រាប់វិនិយោគិនគុណវុឌ្ឍិ បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវអនុវត្តជំពូកទី៤ នៃប្រកាសនេះ និងជំពូកទី៥ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ។

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវបង្ហាញរបាយការណ៍វឌ្ឍនភាពស្តីពីការប្រើប្រាស់សាច់ប្រាក់ដែលបានមកពីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធជាឧបសម្ព័ន្ធនៃរបាយការណ៍ប្រចាំឆ្នាំ។

**ប្រការ១៦ ._**

បុគ្គលចុះបញ្ជីលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធគម្រោងសម្រាប់វិនិយោគិនគុណវុឌ្ឍិ ត្រូវបង្ហាញព័ត៌មានទាន់ពេលដូចមានចែងក្នុងប្រការ២៧ នៃប្រកាសស្តីពីការបោះផ្សាយលក់មូលបត្របំណុលសម្រាប់វិនិយោគិនគុណវុឌ្ឍិ និងករណីមានហេតុការណ៍សំខាន់ៗ ដូចខាងក្រោម៖

១-ការធ្វើបច្ចុប្បន្នភាពលើវឌ្ឍនភាពគម្រោងហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់ហិរញ្ញប្បទានដោយសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ រួមទាំងព្រឹត្តិការណ៍សំខាន់ៗនៃការសាងសង់ ការអភិវឌ្ឍ និងបញ្ហាប្រឈម ឬហានិភ័យដែលអាចប៉ះពាល់ដល់គម្រោង។

២-ហេតុការណ៍សំខាន់ៗដែលអាចប៉ះពាល់ដល់តម្លៃសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ រួមទាំងការផ្លាស់ប្តូរស្ថានភាពហិរញ្ញវត្ថុរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ការពន្យារពេលគម្រោងសំខាន់ៗ ការវិវត្តនៃបទប្បញ្ញត្តិ ឬព្រឹត្តិការណ៍ផ្សេងទៀតដែលអាចប៉ះពាល់ដល់ការបំពេញកាតព្វកិច្ចរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៣-របាយការណ៍ស្តីពីការវាយតម្លៃលទ្ធភាពសងដែលធ្វើបច្ចុប្បន្នភាពដោយភ្នាក់ងារវាយតម្លៃលទ្ធភាពសង។

៤-ការអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ។

៥-ការផ្លាស់ប្តូរពាក់ព័ន្ធនឹងអភិបាលកិច្ចសាជីវកម្មរួមមាន ការផ្លាស់ប្តូររចនាសម្ព័ន្ធ ការផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល និងលាភការនិងប្រាក់បំណាច់របស់អភិបាល និងបុគ្គលិកជាន់ខ្ពស់។

៦-ព័ត៌មានអំពីនិន្នាការក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ការប្រែប្រួលលក្ខខណ្ឌសេដ្ឋកិច្ច និងកត្តាផ្សេងទៀតដែលអាចប៉ះពាល់ដល់ទីផ្សារសញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ។

បុគ្គលចុះបញ្ជីលក់មូលបត្រត្រូវផ្តល់ព័ត៌មានចាំបាច់តាមការតម្រូវដោយ **ន.ម.ភ.**។

## ជំពូកទី៥
## កម្រៃសេវានៃការចុះបញ្ជី

**ប្រការ១៧ ._**

បុគ្គលដាក់ពាក្យស្នើសុំបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ ត្រូវបង់កម្រៃសេវាសិក្សាសំណុំឯកសារ និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាននៅពេលដាក់ពាក្យស្នើសុំជូន **ន.ម.ភ.** ជាប្រាក់ចំនួន ២០.០០០.០០០ (ម្ភៃលាន) រៀល។

**ប្រការ១៨ ៈ**

បុគ្គលដាក់ពាក្យស្នើសុំចុះបញ្ជីឯកសារផ្តល់ព័ត៌មានបន្ថែម និង/ឬឯកសារផ្តល់ព័ត៌មានជំនួសត្រូវបង់កម្រៃសេវាសិក្សាសំណុំឯកសារនៅពេលដាក់ពាក្យស្នើសុំជូន **ន.ម.ក**. ជាប្រាក់ចំនួន ២.០០០.០០០ (ពីរលាន) រៀល។

**ប្រការ១៩ ៈ**

កម្រៃសេវាដូចមានចែងក្នុងប្រការ១៧ និងប្រការ១៨ នៃប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យវិញឡើយ។

## ជំពូកទី៦
## ទណ្ឌកម្ម

**ប្រការ២០ ៈ**

ដោយមិនទាន់គិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទដ្ឋានគតិយុត្តជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា បុគ្គលចុះបញ្ជីលក់មូលបត្រ និង/ឬបុគ្គលពាក់ព័ន្ធ ដែលប្រព្រឹត្តល្មើសប្រការ៧ ប្រការ៨ ប្រការ៩ ប្រការ១៥ និងប្រការ១៦ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំ ការកំណត់ ឬការតម្រូវរបស់ **ន.ម.ក**. ឬបន្តប្រព្រឹត្តល្មើសដដែល ឬប្រព្រឹត្តល្មើសករណីផ្សេងទៀត ត្រូវទទួលទណ្ឌកម្មរដ្ឋបាលដូចមានចែងនៅក្នុងប្រការ២១ នៃប្រកាសនេះ និង/ឬត្រូវទទួលការផាកពិន័យពី **ន.ម.ក**. ជាប្រាក់មិនលើសពី ២៥០.០០០.០០០ (ពីររយហាសិបលាន) រៀល។

ក្នុងករណីមិនរាងចាល បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលការផាកពិន័យទ្វេឡើង។

ក្នុងករណីការប្រព្រឹត្តល្មើសបានបង្កឱ្យមានព្យសនកម្ម បុគ្គលប្រព្រឹត្តល្មើសត្រូវទទួលការផាកពិន័យពី **ន.ម.ក**. និង/ឬជួសជុលសំណងព្យសនកម្មស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

មុននឹងចាត់វិធានការដូចមានចែងក្នុងកថាខណ្ឌទី១ កថាខណ្ឌទី២ និងកថាខណ្ឌទី៣ នៃប្រកាសនេះ **ន.ម.ក**. ត្រូវផ្តល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

**ប្រការ២១ ៈ**

**ន.ម.ក**. អាចដាក់ទណ្ឌកម្មរដ្ឋបាលមានដូចខាងក្រោមៈ

១-ការណែនាំ។

២-ការព្រមានជាលាយលក្ខណ៍អក្សរ។

៣-ការកត់សម្គាល់ជាសាធារណៈ ហើយបញ្ជាឱ្យធ្វើការកែតម្រូវ។

៤-ការដាក់កំហិតលើការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ។

៥-ការប្រកាសជាសាធារណៈនូវទណ្ឌកម្មទៅលើបុគ្គលដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

៦-ការព្យួរ ឬហាមឃាត់នូវការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ ឬការចែកចាយបន្ទាប់។

៧-ទណ្ឌកម្មរដ្ឋបាលផ្សេងទៀត ដែលកំណត់ដោយ **ន.ម.ក**. ស្របតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ២២ .-**

ការអនុវត្តទណ្ឌកម្មរដ្ឋបាល និងការផាកពិន័យដូចមានចែងក្នុងជំពូកទី៦ នៃប្រកាសនេះ មិនរារាំងការអនុវត្តច្បាប់ព្រហ្មទណ្ឌជាធរមាន និងដោយមិនទាន់គិតដល់សំណងនៃការខូចខាតផ្សេងទៀត។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**ប្រការ២៣ .-**

**ន.ម.ភ.** អាចចេញគោលការណ៍ណែនាំស្របតាមច្បាប់ អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមលក្ខខណ្ឌនៃប្រកាសនេះដល់បុគ្គលពាក់ព័ន្ធ អ្នកចូលរួមក្នុងផ្សារមូលបត្រប្រតិស្រុត និងសាធារណជន។

**ប្រការ២៤ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ២៥ .-**

អគ្គលេខាធិការ អគ្គនាយកនិយ័តករ និងប្រធានអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងបុគ្គលពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៤កើត ខែ ជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ៣០ ខែ ឧសភា គ.ស.២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ អ.ស.ហ.
  "ដើម្បីជូនជ្រាប"
- ដូចប្រការ ២៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ